ការិយាល័យកណ្តាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៦ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក និងសាធារណជន មេត្តាទទួលជ្រាបថា កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៦ តាមរយៈ **Video Con-Call** របស់ធនាគារ អេស៊ីលីដា នៅ **ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦** នៅម៉ោង**១៣:០០នាទី ដល់ម៉ោង ១៦:០០នាទី** មានកូរ៉ុមចំនួន **៨១,៩៣** ភាគរយ និងភាគហ៊ុនិកចូលរួមចំនួន **១៥១**នាក់ ស្មើនឹង **៣៥៤.៨៦៩.៩០១** ភាគហ៊ុន។

ភាគហ៊ុនិកបានពិនិត្យ ពិភាក្សា និងអនុម័តដូចខាងក្រោម៖

១. អនុម័តការបែងចែកភាគលាភជាសាច់ប្រាក់ក្នុងចំនួន **៥៥៥ រៀល** ក្នុងមួយភាគហ៊ុន ដែលស្មើនឹង **២៤០,៤០៥,៤៧៥,៥៤៥ រៀល** ស្មើនឹង **២៩.៩៩%** នៃប្រាក់ចំណេញប្រចាំឆ្នាំ២០២៥ ដើម្បីផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ចំនួន **៨០១,៦៤១,៤៦២,០០០ រៀល** និងការរក្សាប្រាក់ចំណេញនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុករបស់ធនាគារ អេស៊ីលីដា បន្ទាប់ពីទទួលបានការអនុម័តពីនិយ័តករពាក់ព័ន្ធ។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៤២ ភាគរយ។***

២. អនុម័តកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ សម្រាប់កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៤៣ ភាគរយ។***

៣. អនុម័តការធ្វើវិសោធនកម្មលើមាត្រា៨ ឧបសម្ព័ន្ធទី៣ និងឧបសម្ព័ន្ធទី៤ នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៣៩ ភាគរយ។***

៤. អនុម័តកម្រៃសេវាសម្រាប់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ស្របតាមអត្រាអតិផរណាប្រចាំឆ្នាំ២០២៥ ចំនួន ២,៥០ភាគរយ។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៣៩ ភាគរយ។***

៥. អនុម័តការដំឡើងប្រាក់បៀវត្សជូនប្រធានក្រុមប្រឹក្សាភិបាលដូចខាងក្រោម៖

- ដំឡើងប្រាក់បៀវត្សជូន **លោកស្រី គឹម សុធារី** ប្រធានក្រុមប្រឹក្សាភិបាល ដោយទទួលបានចំណាត់ថ្នាក់ “A+” ដែលមានប្រសិទ្ធភាពអនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។
- បូកបន្ថែមអត្រាអតិផរណាប្រចាំឆ្នាំ២០២៥ ចំនួន ២,៥០% លើប្រាក់បៀវត្សរបស់ប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាពអនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៧។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៣៩ ភាគរយ។***

៦. អនុម័តការតែងតាំង **បណ្ឌិត អ៊ិន ចាន់នី** ជាអភិបាលប្រតិបត្តិ ធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៣៩ ភាគរយ។***

៧. អនុម័តការតែងតាំង **បណ្ឌិត ហេង ឱណា** ជាអភិបាលឯករាជ្យ ធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៣៩ ភាគរយ។***

៨. អនុម័តគោលការណ៍ភាគលាភ។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៤០ ភាគរយ។***

៩. អនុម័តគោលការណ៍តែងតាំង និងលាភការ។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៣៩ ភាគរយ។***

១០. អនុម័តគោលការណ៍តែងតាំងអភិបាល។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៣៩ ភាគរយ។***

១១. អនុម័តការជ្រើសរើស **KPMG Cambodia Ltd. (“KPMG”)** ជាសវនករឯករាជ្យរបស់ធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ២០២៧។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសំឡេង ៩៥,៤០ ភាគរយ។***

ថ្ងៃព្រហស្បតិ៍ ៧កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**